**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.៥១៣...០២០...៩៨.៩...ធ.ជ.ក

## ចក្ខុវិស័យស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងវិស័យធនាគារឆ្នាំ២០២០ និងទស្សនវិស័យឆ្នាំ២០២១

រៀបចំដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃព្រហស្បតិ៍ ២រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ត្រូវនឹងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

នៅឆ្នាំ២០២០នេះ ការរីករាលដាលនៃជំងឺកូវីដ-១៩ បាននាំឱ្យពិភពលោកជួបនឹងវិបត្តិយ៉ាងធ្ងន់ធ្ងរ ចាប់តាំងពីមហាវិបត្តិសេដ្ឋកិច្ចនៅទសវត្សរ៍ឆ្នាំ១៩៣០ (The Great Depression) មក។ នៅកម្ពុជា រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយទស្សនវិស័យវែងឆ្ងាយនិងម៉ឺងម៉ាត់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានទប់ស្កាត់ការឆ្លងនិងការរីករាលដាលនៃជំងឺកូវីដ-១៩ បានទាន់ពេលវេលានិងមានប្រសិទ្ធភាព។ ទោះយ៉ាងណា សេដ្ឋកិច្ចកម្ពុជា ដែលមានភាពបើកទូលាយនិងពឹងផ្អែកខ្លាំងលើវិស័យខាងក្រៅ (External Sector) បានទទួលរងការធ្លាក់ចុះ បន្ទាប់ពីសម្រេចបានកំណើនខ្ពស់ក្នុងរយៈពេលជាង ២ទសវត្សរ៍ចុងក្រោយ។ វិស័យដែលទទួលរងការធ្លាក់ចុះខ្លាំងជាងគេ រួមមាន វិស័យទេសចរណ៍និងការនាំចេញសម្លៀកបំពាក់ និងស្បែកជើង បន្ទាប់មកគឺវិស័យសំណង់និងអចលនទ្រព្យ ដែលមានសមាមាត្រគាំទ្រកំណើនរហូតដល់ ២/៣។ ទន្ទឹមនេះ លំហូរចូលនៃវិនិយោគផ្ទាល់បរទេស និងការបង្វែរចំណូលពីក្រៅប្រទេសក៏បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ផងដែរ។ វិស័យដែលមានភាពធន់ជាងគេ គឺវិស័យកសិកម្មនិងហិរញ្ញវត្ថុ ដែលបន្តទទួលបានកំណើនវិជ្ជមាន និងបានជួយកាត់បន្ថយផលប៉ះពាល់យ៉ាងគំហុកដល់សេដ្ឋកិច្ច ព្រមទាំងបានរួមចំណែករក្សានិរន្តរភាពអាជីវកម្មនិងការងារ។ ម្យ៉ាងទៀត ការជួយឧបត្ថម្ភសាច់ប្រាក់ចំពោះកម្មករនិយោជិតនិងប្រជាជនក្រីក្រ, ការបន្ធូរបន្ថយពន្ធ និងការចំណាយសាធារណៈលើគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធរបស់រាជរដ្ឋាភិបាល បានរួមចំណែកជួយគាំទ្រប្រជាជនងាយរងគ្រោះ និងសកម្មភាពសេដ្ឋកិច្ចបានមួយផ្នែកទៀតផងដែរ។ គួររំលេចថា ទោះជាមានទំហំតូចនៅឡើយ ការនាំចេញទំនិញសម្រាប់ធ្វើដំណើរនិងផលិតផលមិនមែនកាត់ដេរមួយចំនួនដូចជា គ្រឿងបន្លាស់យានយន្ត គ្រឿងអេឡិចត្រូនិក និងកង់ ជាដើម នៅតែបន្តសម្រេចបានកំណើនល្អដែលគាំទ្រដោយប្រព័ន្ធអនុគ្រោះពន្ធនិងកម្លាំងពលកម្មដែលមានតម្លៃសមរម្យនៅឡើយ។

ក្នុងបរិការណ៍នេះ កំណើនសេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២០ ត្រូវបានប៉ាន់ស្មានថាអាចធ្លាក់ចុះជាងការរំពឹងទុកកាលពីដើមឆ្នាំ ដែលថាអត្រាកំណើនអាចមានកម្រិត -១,៩% ស្របពេលដែលស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាបានព្យាករថានៅក្នុងចន្លោះពី -២% ទៅ -៤%។ ការធ្លាក់ចុះជាងការរំពឹងទុកនេះ ជាចម្បងដោយសារវិស័យទេសចរណ៍មិនមានភាពប្រសើរឡើង ដោយបន្តធ្លាក់ចុះខ្លាំង នៅក្នុងឆមាសទី២ ស្របពេលដែលការនាំចេញក្នុងវិស័យកាត់ដេរ ដែលរួមចំណែករហូតដល់ ៧០% នៃការនាំចេញសរុប បន្តមាននិន្នាការធ្លាក់ចុះ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ចំពោះស្ថានភាពថ្លៃ អត្រាអតិផរណាសម្រាប់ឆ្នាំ២០២០ មានកម្រិតជាមធ្យម ២,៩% ដែលជាចម្បងដោយសារកំណើនថ្លៃម្ហូបអាហារ ជាពិសេសក្នុងអំឡុងពេលមានករណីជំងឺកូវីដ-១៩ ដំបូង និងជំនន់ទឹកភ្លៀង។ អត្រាអតិផរណា ក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការប្រែប្រួលថ្លៃប្រេងអន្តរជាតិផងដែរ ដោយការធ្លាក់ចុះថ្លៃប្រេងបានរួមចំណែកបន្ទាបអត្រាអតិផរណាគួរឱ្យកត់សម្គាល់ ខណៈដែលថ្លៃទំនិញប្រើប្រាស់ដទៃទៀត (អតិផរណាស្នូល) មានស្ថិរភាព។ ជាមួយគ្នានេះ អត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក បានកើនឡើងចាប់តាំងពីចុងឆ្នាំ២០១៩មក ហើយបានបន្តស្ថិតនៅលើគន្លងខ្ពស់ជាងឆ្នាំកន្លងទៅ រហូតដល់ចុងឆ្នាំ២០២០នេះ។ ការកើនឡើងនេះ គឺដោយសារការធ្លាក់ចុះនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ដែលនាំឱ្យមានតម្រូវការប្រាក់រៀលទាប ទាំងសម្រាប់ការប្រើប្រាស់ទូទៅនិងបង់ពន្ធ គួបផ្សំនឹងការថយចុះលំហូរចូលនៃរូបិយប័ណ្ណបរទេសមកកម្ពុជា។ ទោះយ៉ាងណាការធ្លាក់ចុះតម្លៃប្រាក់រៀល មានកម្រិតទាបបើធៀបនឹងរូបិយប័ណ្ណភាគច្រើននៅក្នុងតំបន់។ នាចុងឆ្នាំ២០២០នេះ តម្លៃប្រាក់រៀលបានវិលមកគន្លងដើម ដូចកាលពីឆ្នាំ២០១៦-២០១៨ វិញ (ក្នុងរង្វង់ ៤.០៨៥ រៀលក្នុងមួយដុល្លារអាមេរិក) ដែលគាំទ្រដោយកំណើនតម្រូវការប្រាក់រៀលក្នុងវិស័យកសិកម្ម និងការដាក់ចេញវិធានការរបស់ធនាគារជាតិនៃកម្ពុជា ដែលក្នុងនោះរួមមាន ការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ និងការគ្រប់គ្រងការផ្គត់ផ្គង់ប្រាក់រៀលតាមរយៈឧបករណ៍រូបិយវត្ថុដទៃទៀត។ ការរក្សាបានស្ថិរភាពអត្រាប្តូរប្រាក់បានរួមចំណែករក្សាស្ថិរភាពថ្លៃ និងលំនឹងម៉ាក្រូសេដ្ឋកិច្ច ស្របពេលដែលទុនបម្រុងអន្តរជាតិត្រូវបានគរពូនជាលំដាប់និងមានកម្រិតខ្ពស់ជាង ៣ដងនៃកម្រិតដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន និងមានលទ្ធភាពខ្ពស់ក្នុងការពង្រឹងស្ថិរភាពអត្រាប្តូរប្រាក់និងជំនឿទុកចិត្តមកលើសេដ្ឋកិច្ចកម្ពុជា។

វិស័យហិរញ្ញវត្ថុ ដែលទ្រព្យសកម្មប្រមាណ ៩០% ជាទ្រព្យសកម្មវិស័យធនាគារ បន្តមានវឌ្ឍនភាពនិងភាពធន់ ទោះបីជាទទួលរងសម្ពាធពីការធ្លាក់ចុះនៃវិស័យរូបវន្តក៏ដោយ។ ការពង្រឹងជាបន្តបន្ទាប់នៃបទប្បញ្ញត្តិប្រុងប្រយ័ត្នក្នុងវិស័យធនាគារក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយនេះ ដូចជាការដំឡើងដើមទុន, ការដំឡើងកម្រិតសន្ទនីយភាព និងការការពារហានិភ័យជាប្រព័ន្ធ បានលើកកម្ពស់ភាពរឹងមាំនៃវិស័យនេះ។ ការណ៍នេះបានអនុញ្ញាតឱ្យវិស័យធនាគារបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការរក្សាស្ថិរភាពហិរញ្ញវត្ថុ និងជួយគាំទ្រសកម្មភាពសេដ្ឋកិច្ច ជាពិសេសជួយសម្រាលការលំបាករបស់ប្រជាជនក្រីក្រ និងក្រុមហ៊ុន-សហគ្រាស ដែលប្រឈមនឹងការធ្លាក់ចុះចំណូលតាមរយៈការរៀបចំឥណទានឡើងវិញ។ ជាក់ស្តែង ឥណទានបន្តមានគុណភាពល្អនិងកើនឡើងក្នុងកម្រិតសមស្រប ឆ្លើយតបនឹងតម្រូវការសេដ្ឋកិច្ច ទោះជាមានល្បឿនថយចុះបើធៀបនឹងឆ្នាំកន្លងទៅក៏ដោយ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក៏បន្តផ្តល់សេវានានា ប្រកបដោយពិលាសទាំងក្នុងការទទួលប្រាក់កម្ចី, ការទូទាត់និងការផ្ទេរប្រាក់ជាដើម ដែលបានបន្តរក្សាភាពរឹងមាំនៃជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ។

នៅឆ្នាំ២០២១ មូលនិធិរូបិយវត្ថុអន្តរជាតិរំពឹងថា សេដ្ឋកិច្ចពិភពលោកអាចងើបឡើងវិញ ប៉ុន្តែមានភាពមិនស្មើសាច់នៅឡើយ និងអាចប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់។ បញ្ហាទាំងនេះអាចបន្តដាក់សម្ពាធលើវិស័យខាងក្រៅរបស់កម្ពុជា ដែលក្នុងនោះវិស័យទេសចរណ៍អាចបន្តធ្លាក់ចុះដោយសារការទទួលបានថ្នាំបង្ការទាមទារនូវពេលវេលា, ការលេចចេញមេរោគកូវីដ-១៩ ប្រភេទថ្មី,

ការស្ទាក់ស្ទើរក្នុងការធ្វើដំណើររបស់ទេសចរអន្តរជាតិដោយសារការភ័យខ្លាចឆ្លង និងការថយចុះចំណូលនិងសន្សំ។ វិស័យកម្មន្តសាល រំពឹងថានឹងងើបឡើងជាលំដាប់ ជាពិសេស វិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើង ខណៈដែលវិស័យកសិកម្មរំពឹងថានឹងបន្តមានកំណើនល្អដូចឆ្នាំ២០២០ដែរ។ ទន្ទឹមនេះ ការនាំចេញផលិតផលកសិកម្ម ជាពិសេសអង្ករនិងកៅស៊ូ រំពឹងថាមានសន្ទុះកំណើនខ្ពស់ ដែលគាំទ្រដោយការធ្វើពិពិធកម្មទីផ្សារកសិផលកម្ពុជា និងកំណើនតម្រូវការកៅស៊ូក្នុងស្ថានភាពនៃការប្រសើរឡើងនៃសេដ្ឋកិច្ចពិភពលោក។ វិស័យសំណង់និងអចលទ្រព្យ រំពឹងថាងើបឡើងសន្សឹមៗ ស្របពេលជាមួយនឹងកំណើនវិនិយោគផ្ទាល់បរទេស, ការងើបឡើងវិញនៃចំណូលនិងការរំពឹងទុកពីការរីកចម្រើនសេដ្ឋកិច្ចជារួមនាពេលអនាគត។ ម៉្យាងទៀត វិស័យសណ្ឋាគារនិងភោជនីយដ្ឋាន ក៏ដូចជាវិស័យដឹកជញ្ជូន នឹងអាចបន្តកើនឡើងវិញ ប៉ុន្តែក្នុងល្បឿនយឺត ដោយសារការធ្លាក់ចុះទេសចរអន្តរជាតិ បើទោះបីជាទេសចរក្នុងស្រុកមានភាពសកម្មជាងមុនក៏ដោយ។ ក្នុងបរិការណ៍ដែលថ្នាំបង្ការមានប្រសិទ្ធភាពអាចទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ បានក្នុងឆមាសទី១ ឆ្នាំ២០២១ នោះសេដ្ឋកិច្ចកម្ពុជារំពឹងថានឹងអាចងើបឡើងវិញក្នុងរង្វង់ ៤% ហើយអត្រាអតិផរណារំពឹងថាមានកម្រិតក្រោម ៣% ដែលជាកម្រិតទាបអាចគ្រប់គ្រងបាន ជាមួយនឹងស្ថិរភាពអត្រាប្តូរប្រាក់ និងការរក្សាបានកម្រិតខ្ពស់នៃទុនបម្រុងអន្តរជាតិ។ ចំណែកឯ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានាបានព្យាករថា អត្រាកំណើនសេដ្ឋកិច្ចកម្ពុជាអាចសម្រេចបានពី ៤% ទៅ ៦,៨%។ ទោះយ៉ាងណា ការព្យាករទាំងនេះអាស្រ័យជាចម្បងលើប្រសិទ្ធភាពនៃថ្នាំបង្ការ, ល្បឿននៃការងើបឡើងវិញនៃកំណើនក្នុងប្រទេសជាដៃគូសេដ្ឋកិច្ចជាមួយកម្ពុជា និងការពង្រឹងមូលដ្ឋានសេដ្ឋកិច្ចក្នុងស្រុក។

ស្ថិតក្នុងបរិការណ៍ខាងលើនេះ ការបន្តពង្រឹងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកថែមទៀតនឹងជួយទ្រទ្រង់និងបន្ថយការប៉ះពាល់លើកំណើនសេដ្ឋកិច្ចកម្ពុជា ដោយសារការធ្លាក់ចុះវិស័យខាងក្រៅ។ ដូច្នេះ ការបន្តអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម, ការជំរុញនវានុវត្តន៍ និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗលើគ្រប់វិស័យ មានសារសំខាន់ណាស់ក្នុងការពង្រឹងមូលដ្ឋានកំណើនសកម្មភាពក្នុងស្រុក។ ជាមួយគ្នានេះ វិស័យកសិកម្មនឹងបន្តជាវិស័យដ៏សំខាន់ និងមានសក្តានុពលខ្ពស់ ដែលអាចជួយស្រូបឥទ្ធិពលមួយផ្នែកនៃវិបត្តិ ដូចជាភាពអត់ការងារធ្វើ ឬជួយគាំទ្រជីវភាពប្រជាជនក្រីក្រ។ ម៉្យាងទៀត ការពន្លឿនការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច និងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហកម្ម នឹងជួយឱ្យសេដ្ឋកិច្ចកម្ពុជាងើបឡើងកាន់តែឆាប់រហ័សពីវិបត្តិនាបច្ចុប្បន្ននេះ។ លើសពីនេះ ការចាប់ផ្តើមទទួលបានចំណូលពីការផលិតប្រេងនៅកម្ពុជានឹងផ្តល់ជាប្រភពថវិកាជាតិមួយទៀត សម្រាប់ការអភិវឌ្ឍវិស័យអាទិភាពនានានៅពេលខាងមុខ។

សំខាន់ដូចគ្នានេះ វិស័យធនាគារនិងហិរញ្ញវត្ថុនឹងបន្តដើរតួនាទីគន្លឹះមួយ ក្នុងការគាំទ្រសកម្មភាពសេដ្ឋកិច្ច ព្រមទាំងរួមចំណែករក្សាលំនឹងម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ លើសពីនេះ ការរំពឹងពីការងើបឡើងនៃកំណើនសេដ្ឋកិច្ចនឹងអាចបន្ថយសម្ពាធមកលើវិស័យធនាគារ ជាពិសេសលទ្ធភាពបង្កើនឥណទាននិងទទួលបានប្រាក់បញ្ញើខ្ពស់ជាងឆ្នាំ២០២០។ ទោះយ៉ាងណា ការថយចុះចំណូលនិងសន្សំនៅឆ្នាំ២០២០ នឹងអាចបង្កើនបំណុលរបស់ប្រជាជន ដែលបញ្ហានេះអាចបង្កជាហានិភ័យចម្បងមួយ ដូចដែលប្រទេសកំពុងអភិវឌ្ឍន៍នានាបាននិងកំពុងប្រឈមក្នុងដំណាក់កាល

ក្រោយវិបត្តិកូវីដ-១៩ ដូច្នេះដែរ។ ម៉្យាងទៀត ភាពមិនប្រាកដប្រជានៃវិស័យសេដ្ឋកិច្ចមួយចំនួនដែលទទួលរងឥទ្ធិពលនៃជំងឺកូវីដ-១៩ ក៏អាចនាំឱ្យហានិភ័យកើនឡើងចំពោះវិស័យធនាគារផងដែរ។ ឆ្លើយតបនឹងបញ្ហានេះ ធនាគារជាតិនៃកម្ពុជានឹងបន្តពង្រឹងការត្រួតពិនិត្យប្រព័ន្ធធនាគារ និងបានត្រៀមដាក់ចេញវិធានការប្រុងប្រយ័ត្ននិងការគាំទ្រចាំបាច់នានា ដើម្បីរក្សាចីរភាព ភាពធន់ និងទំនុកចិត្តមកលើប្រព័ន្ធធនាគារកម្ពុជា។ ទន្ទឹមនេះ ប្រព័ន្ធធនាគារនឹងបន្តផ្តល់ឥណទានប្រកបដោយការទទួលខុសត្រូវខ្ពស់, លើកកម្ពស់ការយល់ដឹងផ្នែកហិរញ្ញវត្ថុរបស់សាធារណជន, ពង្រឹងកិច្ចគាំពារអតិថិជន និងបង្កើនគុណភាពនិងតម្លាភាពនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដែលនឹងរួមចំណែករក្សាស្ថិរភាពហិរញ្ញវត្ថុឱ្យបានរឹងមាំ និងចៀសផុតពីបញ្ហាបំណុលវណ្ណកបស់ប្រជាពលរដ្ឋ។

ម៉្យាងវិញទៀត សេដ្ឋកិច្ចកម្ពុជានៅបន្តមានកម្រិតដុល្លារូបនីយកម្មខ្ពស់នៅឡើយ បើទោះបីជាសម្រេចបានវឌ្ឍនភាពល្អកន្លងមកក៏ដោយ ដូចជា ការបិទស្លាកថ្លៃទំនិញនិងសេវាជាប្រាក់រៀល, ការបង្កើនការផ្តល់កម្ចី និងការទូទាត់សេវាសាធារណៈជារៀល។ ការប្រើប្រាស់ប្រាក់រៀលឱ្យកាន់តែទូលំទូលាយនឹងគាំទ្រដល់ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយរូបិយវត្ថុនិងសារពើពន្ធ ជាពិសេសក្នុងដំណាក់កាលស្តារនិងជំរុញសកម្មភាពសេដ្ឋកិច្ច ដូចជា តាមរយៈការកាត់បន្ថយអត្រាការប្រាក់នៅលើទីផ្សារ, ការចាក់បញ្ចូលសាច់ប្រាក់នៅក្នុងសេដ្ឋកិច្ច និងការប្រមូលទុនដោយការបោះផ្សាយមូលបត្ររដ្ឋ ជាដើម។ ក្នុងន័យនេះ ការរៀបចំក្របខ័ណ្ឌនិងយន្តការបោះផ្សាយមូលបត្ររដ្ឋ និងការជំរុញការប្រើប្រាស់ប្រាក់រៀល នឹងអនុញ្ញាតឱ្យរាជរដ្ឋាភិបាលទទួលបានហិរញ្ញប្បទានរយៈពេលវែងបន្ថែមទៀត ហើយផ្តល់លទ្ធភាពដល់ធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុឱ្យកាន់តែមានប្រសិទ្ធភាពផ្អែកលើយន្តការទីផ្សារ។

គួររំលេចថា វិបត្តិជំងឺកូវីដ-១៩ ក៏បានផ្លាស់ប្តូររបៀបនៃការរស់នៅ ទំនាក់ទំនង និងដំណើរការសេដ្ឋកិច្ច ហើយបាននាំទៅរកប្រក្រតីថ្មី ដែលក្នុងនោះការប្រើប្រាស់បច្ចេកវិទ្យាទទួលបានការពេញនិយមនិងអាចក្លាយជាប្រភពកំណើនសក្តានុពលថ្មីសម្រាប់សេដ្ឋកិច្ច។ ក្នុងស្ថានភាពនេះ ធនាគារជាតិនៃកម្ពុជាក៏បានអភិវឌ្ឍប្រព័ន្ធទូទាត់ ផ្អែកលើបច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗ ដែលបាននិងកំពុងដើរតួនាទីកាន់តែសំខាន់ក្នុងការសម្រួលនិងគាំទ្រកំណើនប្រតិបត្តិការដោះដូរ, ការវិនិយោគនិងពាណិជ្ជកម្មអន្តរជាតិ។ ទំនើបកម្មប្រព័ន្ធទូទាត់និងការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុថ្មី នឹងរួមចំណែកគាំទ្រដល់សេដ្ឋកិច្ចឌីជីថលរបស់រាជរដ្ឋាភិបាលផងដែរ។ ក្នុងចំណោមប្រព័ន្ធទូទាត់ដែលកម្ពុជាបានដាក់ឱ្យប្រើប្រាស់កន្លងមក ប្រព័ន្ធបាគងដែលប្រើប្រាស់បច្ចេកវិទ្យាប្លុកឆេន (Blockchain) ត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជាប្រព័ន្ធទូទាត់មួយដែលប្រើប្រាស់បច្ចេកវិទ្យាចុងក្រោយនៅលើពិភពលោក។ ប្រព័ន្ធបាគងកំពុងក្លាយជាប្រព័ន្ធទូទាត់កន្លែងមួយ ដែលសម្រួលដល់ការផ្ទេរប្រាក់និងទូទាត់សងប្រាក់ជាមួយគ្រប់គ្រឹះស្ថាននិងប្រតិបត្តិករផ្តល់សេវាទូទាត់។ ទោះយ៉ាងណា ការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុថ្មីៗទាមទារឱ្យមានការប្រុងប្រយ័ត្នខ្ពស់ទាំងចំពោះគ្រឹះស្ថានផ្តល់សេវាហិរញ្ញវត្ថុនិងអតិថិជន ដើម្បីចៀសវាងពីហានិភ័យនានា ជាពិសេសឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា (Cybercrime)។